## អរិយធម៌ផាធៀន (Parthian civilization)

ប្រវត្តិសាស្ត្រនៃអរិយធម៌ផាធៀន(Parthian) គឺចាប់ផ្តើមបន្ទាប់ពីអរិយធម៌ពែក្ស[១] ត្រូវបានដួលរលំនៅចុងស.វ.ទី៤មុនគ.ស.។[២] នៅដើមស.វ.ទី៣មុនគ.ស. អរិយធម៌ផាធៀនចាប់ផ្តើមមានឥទ្ធិពលខ្លាំងនៅលើទឹកដីនៃអរិយធម៌ពែក្ស ដែលបច្ចុប្បន្នជាប្រទេសអ៊ីរ៉ាក់(Iraq)។ រីឯវិសាលភាពទឹកដីនៃអរិយធម៌នេះមានឥទ្ធិពលចាប់តំបន់ទន្លេ អឺប្រាត រហូតទន្លេឥណ្ឌុស និងរួមបញ្ចូលទាំងអ៊ីរ៉ាក់ អ៊ីរ៉ង់ និងតំបន់ខ្លះនៃប្រទេសអាហ្វហ្គានីស្ថាន។[៣] នៅក្រោយពេល Alexander the Great បានស្លាប់ មានមេទ័ពរបស់គាត់ម្នាក់ឈ្មោះថា សេលូសទី១ (Seleucus I) ចាប់ផ្តើមមានឥទ្ធិពល អំណាច និងវាយគ្រប់គ្រងផ្នែកខ្លះនៃតំបន់មេសូប៉ូតាមី និងពែក្ស ដោយបង្កើតបានជារាជ្យវង្ស សេលូស (Seleucus)។ ក្រោយមក រាជវង្ស សេលូស បានបង្កើតជាអាណាចក្រមួយដែលហៅថា ផាធៀន (រូបលេខ១)។

ទីក្រុងនៅក្នុងអរិយធម៌ផាធៀននេះ គឺមាន២សំខាន់ៗរួមមានទីក្រុងសេស៊ីផុន (Ctesip-hon) និងទីក្រុង ហាត្រា(Hatra) (រូបលេខ២-៤)។

Ctesiphon គឺជាអតីតរាជធានីនៃអរិយធម៌ពីរផ្សេងគ្នាគឺ ផាធៀន និងសាសានៀន (Sasanians) ក្នុងអំឡុងពេល៨០០ឆ្នាំ។ ទីក្រុងមានទីតាំងស្ថិតនៅខាងជើងនៃទន្លេ (Tigris) និងចម្ងាយប្រមាណ៣២គីឡូពីរាជធានី បាកដាដ (Baghdad)។ នៅទីនេះឃើញមានសំណង់ដ៏ធំមួយដែលហៅថា Ṭāq Kisrā ដោយអ្នកស្រាវជ្រាវបានដឹងថា ជាព្រះរាជវាំងនៃផាធៀន និងស្តេច Khosrow I នៃអរិយធម៌សាសានៀនជាដើម។[៤] ទីក្រុងនេះគឺជាតំបន់ស្នូលដ៏សំខាន់

---

[១] https://ams.com.kh/khmercivilization/detail/14489

[២] https://www.iranchamber.com/history/parthians/parthians.php

[៣] https://www.worldhistory.org/Parthia_(Empire)/

[៤] https://www.britannica.com/place/Ctesiphon-ancient-city-Iraq

អត្ថបទដោយ៖ អេង តុលា

នៃអរិយធម៌ផាធៀន និងសាសានៀន ព្រោះជាតំបន់ពាណិជ្ជកម្មដែលតភ្ជាប់ទីផ្សារទំនាក់ទំនងជាមួយតំបន់អឺរ៉ុប។[៥]

រីឯ ហាត្រា (Hatra) គឺជាទីក្រុងធំទី២បន្ទាប់ពី Ctesiphon នៃអរិយធម៌ផាធៀន និងជារាជធានីនៃអាណាចក្រអារ៉ាប់។ ទីក្រុងនេះមានទីតាំងស្ថិតនៅក្នុងតំបន់ Al-Jazīrah និងមានចម្ងាយប្រមាណ២៩០ខាងកើតពីរាជធានី បាកដាដ (Baghdad) ។ ទីក្រុងនេះប្រហែលកសាងដំបូងនៅក្នុងរាជវង្ស Seleucid នៅស.វ.ទី៣មុនគ.ស. ក្រោយមកបានក្លាយជារាជធានីដ៏សំខាន់នៃអរិយធម៌ផាធៀន។[៦] ទីក្រុងនេះមានការឈ្លានពានពីសំណាកពួករ៉ូមាំងនៅឆ្នាំ ១១៦ និង១៩៨នៃគ.ស.។ សំណង់ស្ថាបត្យកម្មសំខាន់នៅក្នុងទីក្រុងឃើញទទួលឥទ្ធិពលពីអរិយធម៌ក្រិច និងរ៉ូមាំង។[៧] ដូចដែលយើងបានដឹងហើយថា សិល្បៈវប្បធម៌នៃអរិយធម៌រ៉ូមាំង និងក្រិច គឺភាគច្រើនជាសំណង់សសរ។

គួរបញ្ជាក់ដែរថា សិល្បៈវប្បធម៌នៃអរិយធម៌ផាធៀន គឺកើតពីអរិយធម៌ពែក្ស និងសិល្បៈពីអរិយធម៌ក្រិច-រ៉ូមាំង ដែលជាអរិយធម៌ដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រ។ តាមរយៈសំណង់ស្ថាបត្យកម្ម សិល្បៈដែលបានបន្សល់ពីអរយិធម៌ផាធៀន អ្នកស្រាវជ្រាវបានបង្ហាញ អរិយធម៌នៃអាណាចក្រផាធៀននេះមានឥទ្ធិពលខ្លាំងក្លា និងរុងរឿង នៅតំបន់សមុទ្រមីឌីទែរ៉ាណេនៅអំឡុងស.វទី៣មុនគ.ស.រហូតដល់ស.វទី៣នៃគ.ស.។[៨]

ជនជាតិផាធៀនបុរាណ បានបង្កើតសិល្បៈរបស់ខ្លួនក្នុងតាមទម្រង់ផ្សេងៗដែលបានរកឃើញពីកន្លែងជាច្រើននៃអរិយធម៌នេះរួមមាន សិល្បៈនៃការស្មូនដីធ្វើជា គ្រឿងអលង្ការ រូបចម្លាក់អំពីថ្ម លោហៈធាតុ កាក់ និងអំពីដីឥដ្ឋជាដើម(រូបលេខ៥-៧)។ ជាពិសេស

[៥] https://www.metmuseum.org/toah/hd/ctes/hd_ctes.htm

[៦] https://www.britannica.com/place/Hatra

[៧] https://whc.unesco.org/en/list/277

[៨] https://www.metmuseum.org/toah/hd/ctes/hd_ctes.htm

សំណង់ស្ថាបត្យកម្មសំខាន់ៗនៃអរិយធម៌មួយនេះ ដែលមានដូចជា (Ctesip-hon) និងទីក្រុងហាត្រា( Hatra)។

សរុបមកអរិយធម៌ផាធៀនកកើតឡើងនៅពាក់កណ្តាលនៃស.វ.ទី៣មុនគ.ស រហូតដល់ស.វ.ទី៣នៃគ.ស.។ អរិយធម៌នេះត្រូវបានដួលរលំដោយអរិយធម៌សាសានៀននៅពាក់កណ្តាលនៃស.វ.ទី៣។






រូបលេខ១-២៖ ផែនទីនៃវិសាលភាពអាណាចក្រផាធៀនបុរាណ និងទីក្រុង Ctesiphon

ប្រភព៖https://www.britannica.com/place/Hatra

អត្ថបទដោយ៖ អេង តុលា



រូបលេខ៣-៥៖ សំណង់ស្ថាបត្យកម្មក្នុងទីក្រុង Hatra និងវត្ថុសិល្បៈក្នុងអរិយធម៌ផាធៀន

ប្រភព៖https://www.britannica.com/place/Hatra , www.metmuseum.org





រូបលេខ២៦-៧៖ ផ្តែរដែលក្នុងឥទ្ធិពលអរិយធម៌
ពែក្ស និងកុលាលភាជន៍
ប្រភព៖ www.metmuseum.org

# ឯកសារយោង

https://ams.com.kh/khmercivilization/detail/14489

https://www.iranchamber.com/history/parthians/parthians.php

https://www.worldhistory.org/Parthia_(Empire)/

https://www.britannica.com/place/Ctesiphon-ancient-city-Iraq

https://www.metmuseum.org/toah/hd/ctes/hd_ctes.htm

https://www.britannica.com/place/Hatra

https://whc.unesco.org/en/list/277

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា